ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩)
លេខ៖ ៣៨១/២២ (គ.វ.ក-១៩)

# សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្អាកជាបណ្តោះអាសន្នចូលការចាក់វ៉ាក់សាំងកូវីដ-១៩ ចំនួន ០៣ថ្ងៃ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២

**យោង៖** ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ លើរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំរបស់គណៈប្រចាំការ នៃ គ.ប.ក កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ គ.វ.ក-១៩សូមជម្រាបជូនបងប្អូនប្រជាពលរដ្ឋ កម្មករ កម្មការិនី សិស្ស និស្សិត នៅទូទាំងប្រទេសឱ្យបានជ្រាបថា ការងារចាក់វ៉ាក់សាំងកូវីដ-១៩ នៅទូទាំងប្រទេសត្រូវបានផ្អាកជាបណ្តោះអាសន្ន ចំនួន ០៣ថ្ងៃ ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ ដើម្បីសម្រួលដល់ប្រជាពលរដ្ឋ និងក្រុមការងារចាក់វ៉ាក់សាំងទាំងអស់ អាចធ្វើដំណើរទៅចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២ ខាងមុខនេះ នៅមូលដ្ឋានរបស់ខ្លួនរៀងៗខ្លួន។ ការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនប្រជាជនត្រូវដំណើរការជាប្រក្រតីឡើងវិញចាប់ពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ ដោយក្រុមការងារត្រូវរៀបចំឱ្យបានរួចរាល់ដើម្បីធានាបានថាប្រជាជនអាចមកចាក់វ៉ាក់សាំងវិញបាននៅថ្ងៃទី០៧ ខែមិថុនា នេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនប្រជាពលរដ្ឋ កម្មករ កម្មការិនី សិស្ស និស្សិត ទាំងអស់ ជ្រាបជាព័ត៌មាន។

ថ្ងៃ សៅរ៍ ២ រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០២២
**រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការ ចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ (គ.វ.ក-១៩)**

វេជ្ជ. ឱ្យ វណ្ណឌីន